ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ...១៧៦...ស.ខល

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល

## ស្តីពី

## ការអនុញ្ញាតឲ្យសេវាសុខាភិបាលឯកជនស្របច្បាប់ (មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល និងសម្ភព) ប្រើប្រាស់ Rapid Antigen Test COVID-19 ក្នុងក្របខណ្ឌទូទាំងប្រទេស

យោងតាមសំណើរបស់សមាគមអ្នកផ្តល់សេវាសុខាភិបាលឯកជននៅកម្ពុជា ដែលមានលិខិតលេខ ០០៧/២១ ស.ស.ឯ.ក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ ស្តីពីការសុំអនុញ្ញាតឱ្យសេវាសុខាភិបាលឯកជន ប្រើប្រាស់ Rapid Antigen test Covid-19 នៅតាមបណ្តាមូលដ្ឋានសេវាសុខាភិបាលឯកជនស្របច្បាប់ (មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល និងមន្ទីរសម្ភព) ក្នុងក្របខណ្ឌទូទាំងប្រទេស និងដោយមានការឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងសុខាភិបាលអនុញ្ញាតឲ្យសេវាសុខាភិបាលឯកជនស្របច្បាប់ខាងលើ ប្រើប្រាស់ Rapid Antigen test Covid-19 ដែលបានទទួលស្គាល់ និងកំពុងប្រើប្រាស់ដោយក្រសួងសុខាភិបាល។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធាន**

**គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

ម៉ម_ប៊ុនហេង

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- គណៈកម្មការជាតិគ្រប់គ្រង និងដឹកនាំការអនុវត្តវិធានការ បិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល
- សមាគមអ្នកផ្តល់សេវាសុខាភិបាលឯកជននៅកម្ពុជា
- ឯកសារ-កាលប្បវត្តិ